# ផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០

## ក.និដ្ឋភាពរួមទូទៅ

ប្រទេសកម្ពុជា មានប្រជាជនប្រមាណ ១៥,៥លាននាក់ ដែលភាគច្រើនជាយុវជន ក្នុងនោះ ៥៥,៨% មានអាយុក្រោម៣០ឆ្នាំ[1] និងមានប្រព័ន្ធស្បៀងចម្រុះនិងមានមុខម្ហូបសម្បូរបែបក្នុងប្រវត្តិសាស្ត្រ។ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ទោះបីប្រទេសកម្ពុជាសម្រេចបាននូវសមិទ្ធកម្មសេដ្ឋកិច្ចដ៏ខ្លាំងក្លា និងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងមានវិសាលភាពកាន់តែទូលំទូលាយ ហើយបានកាត់បន្ថយភាពក្រីក្រក្នុងអត្រាមួយដ៏ខ្ពស់ ប៉ុន្តែវិសមភាពកនៅតែបន្តមាននៅឡើយ ហើយប្រជាពលរដ្ឋ២២%នៅពុំអាចមានលទ្ធភាពទទួលបានរបបអាហារសុខភាព។[2] អត្រាកង្វះអាហារូបត្ថម្ភនៅមានកម្រិតខ្ពស់ក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ ក្នុងនោះកុមារ៣២,៤%មានបញ្ហាក្រិសក្រិន ២៤%មានទម្ងន់មិនគ្រប់ និង១០%មានបញ្ហាស្គមស្គាំង។[3] អត្រានៃភាពក្រីក្រនិងបញ្ហាអាហារូបត្ថម្ភ ប្រែប្រួលខុសគ្នាពីខេត្តមួយទៅខេត្តមួយ ហើយតួលេខខ្ពស់មាននៅតាមតំបន់ភ្នំតាមបណ្តោយព្រំដែន។ កម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ ដែលងាយរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ ជាពិសេសដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។

គោលនយោបាយនិងយុទ្ធសាស្ត្រនានា ដែលបាននិងកំពុងអនុវត្តន៍នៅកម្ពុជា ផ្តោតលើកត្តាជាច្រើនដែលនាំឱ្យមានការផ្លាស់ប្តូរប្រព័ន្ធស្បៀងនិងផ្តល់នូវក្របខ័ណ្ឌ ដើម្បីជំរុញឱ្យមានការធ្វើសកម្មភាពតាមវិស័យនានា។ ផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងនេះ ផ្សារភ្ជាប់ទៅនឹងបណ្តាក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់ ហើយកំណត់នូវអាទិភាពតម្រូវឱ្យមានការពន្លឿនសកម្មភាពរួមគ្នាក្រោមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ លើកទី២ ឆ្នាំ២០១៩-២០២៣ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ និងយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធនានា រួមមាន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥។ល។ វិស័យកសិកម្មនិងរបបអាហារសុខភាព បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងប្រព័ន្ធស្បៀងរបស់កម្ពុជា ដើម្បីឆ្លើយតបនៅក្នុងដំណាក់កាលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩និងក្នុងដំណាក់កាលស្តារឡើងវិញក្រោយវិបត្តិនេះ ។

ផែនទីបង្ហាញផ្លូវនេះ គឺជាលទ្ធផលនៃកិច្ចសន្ទនានិងការវិភាគ ដែលបានរៀបចំឡើងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ នៅក្នុងឆ្នាំ២០២១ កិច្ចសន្ទនាចំនួន៣០លើក ត្រូវបានរៀបចំឡើង ដោយមានអ្នកចូលរួម

---

[1] វិទ្យាស្ថានជាតិស្ថិតិ, 2019 < https://www.nis.gov.kh/nis/Census2019/Final%20General%20Population%20Census%202019-English.pdf>

[2] CARD, MAFF, WFP FNG, 2017 <https://docs.wfp.org/api/documents/WFP-0000070325/download/>

[3] ការអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា, 2014-15 < https://dhsprogram.com/pubs/pdf/fr312/fr312.pdf>

ប្រមាណ ២០០០នាក់។ វឌ្ឍនភាពដែលសម្រេចបាននេះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវពីរាជរដ្ឋាភិបាលរួមនឹងការចាត់តាំងឯកឧត្តម **សុខ ស៊ីឡូ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ធ្វើជាអ្នកកោះប្រជុំថ្នាក់ជាតិស្តីពីប្រព័ន្ធស្បៀងកាលពីខែវិច្ឆិកាឆ្នាំ២០២០។ សកម្មភាពមួយចំនួនដែលកម្ពុជាបានរៀបចំរួចមុនកិច្ចសន្ទនាស្តីពីប្រព័ន្ធស្បៀង មានដូចជា ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ឆ្នាំ២០១៩-២០២៣ ក្រោមការសម្របសម្រួលដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ការចូលរួមគាំទ្រពីចលនាបង្កើនអាហារូបត្ថម្ភ និងវេទិកាយុវជនដែលបានរៀបចំឡើងពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០។ កិច្ចសន្ទនាភាគច្រើនត្រូវបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ ដោយគោរពតាមវិធានការរបស់ក្រសួងសុខាភិបាលស្តីពីការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។

## ខ. ចក្ខុវិស័យស្តីពីប្រព័ន្ធស្បៀងប្រកបដោយចីរភាពនៅកម្ពុជា ឆ្នាំ២០៣០

*ត្រឹមឆ្នាំ២០៣០ ប្រជាពលរដ្ឋកម្ពុជានឹងទទួលបានរបបអាហារសុខភាព និងអាហារប្រកបដោយសុវត្ថិភាព ដោយមានការយកចិត្តទុកដាក់ជាចម្បងលើស្ត្រីនិងកុមារ ដើម្បីបំបែកវដ្តអន្តរជំនាន់នៃបញ្ហាអាហារូបត្ថម្ភ និងឆ្លើយតបទៅនឹងដំណើរការប្រែប្រួលអាហារូបត្ថម្ភ។ ប្រព័ន្ធស្បៀងនឹងផ្តល់នូវសារជាតិចិញ្ចឹមដល់ប្រជាពលរដ្ឋកម្ពុជា ពង្រឹងផលិតកម្មក្នុងស្រុកនិងការចែកចាយ បង្កើតឱកាសធ្វើពាណិជ្ជកម្មនិងការប្រកបអាជីវកម្មក្នុងនិងក្រៅប្រទេស ផ្តល់ឱកាសប្រកបរបរចិញ្ចឹមជីវិតប្រកបដោយសមធម៌ជាពិសេសសម្រាប់យុវជន ធន់នឹងភាពងាយរងគ្រោះ វិបត្តិ និងបញ្ហាផ្សេងៗ ការពារបរិស្ថាន និងកាត់បន្ថយកត្តាបង្កនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការជំរុញឱ្យប្រព័ន្ធស្បៀងឆ្ពោះទៅរកការអភិវឌ្ឍបៃតង។*[4]

ការសម្រេចចក្ខុវិស័យឱ្យបានត្រឹមឆ្នាំ២០៣០ ទាមទារឱ្យមានការពង្រីកលទ្ធភាពទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភ ការផ្តល់ជំនួយសង្គមនិងការអប់រំ និងការធានាយ៉ាងណាឱ្យវិស័យកសិកម្មនិងខ្សែច្រវាក់តម្លៃស្បៀងមានភាពចម្រុះនិងមានផលិតភាពខ្ពស់ មានចីរភាព គាំទ្រដល់របបអាហារសុខភាព រួមចំណែកដល់កំណើនសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងផ្តល់ឱកាសការងារដល់ជនក្រីក្រនិងជនងាយរងគ្រោះ។ កត្តាសំខាន់សម្រាប់ធ្វើទំនើបកម្មវិស័យកសិកម្មនិងប្រព័ន្ធស្បៀងនៅកម្ពុជា គឺនវានុវត្តន៍ និងការវិនិយោគលើប្រព័ន្ធឌីជីថល បច្ចេកវិទ្យាទំនើប និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា។

## គ. អាទិភាពចំនួនបួន ដែលបានលេចចេញពីកិច្ចសន្ទនាថ្នាក់ជាតិ

១. លើកកម្ពស់របបអាហារសុខភាពសម្រាប់ទាំងអស់គ្នា
២. លើកកម្ពស់ភាពអង់អាចរបស់យុវជន ស្ត្រី និងជនងាយរងគ្រោះ

[4] កំណើនសេដ្ឋកិច្ចដែលធានាបាននូវចីរភាពបរិស្ថាន។

៣. ពង្រឹងភាពធន់លើមុខរបរចិញ្ចឹមជីវិតនិងប្រព័ន្ធស្បៀង
៤. ពង្រឹងអភិបាលកិច្ចដើម្បីធ្វើឱ្យប្រព័ន្ធស្បៀងកាន់តែមានបរិយាប័ន្ន។

ដើម្បីទទួលបានជោគជ័យ យើងត្រូវធ្វើការងាររួមគ្នាលើគ្រប់វិស័យជាមួយនឹងតួអង្គពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងសហគមន៍ ដើម្បីកាត់បន្ថយភាពក្រីក្រ បញ្ចប់ភាពអត់ឃ្លាននិងលុបបំបាត់បញ្ហាអាហារូបត្ថម្ភ និងការពារបរិស្ថាន។ សំខាន់ជាងនេះ យើងត្រូវជំរុញឱ្យមានការចូលរួមពីយុវជន ស្ត្រី អ្នកប្រើប្រាស់និងអ្នកផលិត ជនជាតិដើមភាគតិច និងជនងាយរងគ្រោះ និងយកមតិយោបល់របស់គាត់ ដើម្បីរៀបចំប្រព័ន្ធស្បៀងសម្រាប់អនាគត ដើម្បីធ្វើឱ្យមនុស្ស ភពផែនដីកាន់តែមានសុខភាពមាំមួន សេដ្ឋកិច្ចរីកចម្រើនប្រកបដោយសមធម៌និងវិបុលភាព។ ផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងប្រកបដោយចីរភាពឆ្នាំ២០៣០ បានផ្តល់នូវវិធីសាស្ត្រល្អៗសម្រាប់បង្កើតនូវគោលនយោបាយនិងផែនការសកម្មភាពតាមវិស័យថ្មីៗ និងផ្តល់នូវក្របខ័ណ្ឌមួយ ដើម្បីកំណត់កត្តាដែលនាំមកនូវការផ្លាស់ប្តូរសំខាន់ៗ និងការអនុវត្តតាមដំណាក់កាលនីមួយៗ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវនេះ។

## ឃ. អាទិភាពសម្រាប់កម្ពុជាឆ្ពោះទៅឆ្នាំ២០៣០

### ១. លើកកម្ពស់របបអាហារសុខភាពសម្រាប់ទាំងអស់គ្នា

**កម្ពុជានឹងបន្តខិតខំធ្វើការអភិវឌ្ឍលើគ្រប់វិស័យសំខាន់ៗ ដើម្បីធានាឱ្យមានរបបអាហារសុខភាព និងអាហារដែលមានសុវត្ថិភាព ងាយស្រួលទទួលរកបានសម្រាប់ទាំងអស់គ្នា ជាពិសេសសម្រាប់ស្ត្រី កុមារនិងជនងាយរងគ្រោះ ដើម្បីឆ្លើយតបចំពោះបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់។** ដើម្បីធ្វើឲ្យសម្រេចគោលដៅនេះ ទាមទារឱ្យមានការធ្វើសកម្មភាពជាពហុវិស័យ តាមរយៈការផ្តល់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការពង្រីកការទទួលបានសេវាសុខភាពនិងសេវាអាហារូបត្ថម្ភ ការបង្កើតឱកាសការងារ ការលើកកម្ពស់ចំណេះដឹងអ្នកប្រើប្រាស់និងការអប់រំ ការលើកកម្ពស់ទំនើបកម្មវិស័យកសិកម្មនិងខ្សែច្រវាក់តម្លៃស្បៀង ការធ្វើពិពិធកម្មគ្រប់មុខដំណាំប្រកបដោយបរិយាប័ន្ននិងប្រកួតប្រជែង ការលើកកម្ពស់ការផលិតអាហារសុខភាពនិងអាហារសុវត្ថិភាព ការផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងការរៀបចំទម្លាប់រស់នៅប្រកបដោយអនាម័យល្អ តាមរយៈការលើកម្ពស់ការយល់ដឹងនិងការពង្រឹងគុណភាពប្រព័ន្ធនានា ព្រមទាំងការផ្តល់ជំនួយសង្គម។ ទោះបីកម្ពុជា ជាប្រទេសដែលមានប្រព័ន្ធស្បៀងចម្រុះនិងសម្បូរដោយអាហារដែលមានសុវត្ថិភាពនិងមានសារជាតិចិញ្ចឹម ប៉ុន្តែគ្រួសារក្រីក្រមួយចំនួនពុំមានលទ្ធភាពរកបានអាហារដែលមានសុវត្ថិភាព និងសម្បូរសារជាតិចិញ្ចឹមបានគ្រប់គ្រាន់ទេ។

ក. **កត្តាដែលនាំមកនូវការផ្លាស់ប្តូរប្រព័ន្ធស្បៀង៖** ១).ត្រូវមានការរៀបចំរបបអាហារសុខភាពឱ្យមានកាន់តែច្រើននិងដែលអាចងាយស្រួលរកបាន តាមរយៈការបង្កើនផលិតភាពនិងការធ្វើពិពិធកម្មវិស័យកសិកម្ម កសិឧស្សាហកម្ម ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ ការផ្គត់ផ្គង់អាហារសុវត្ថិភាព ការបញ្ចូល

មីក្រូសារជាតិទៅក្នុងអាហារ ការបន្ថែមតម្លៃទៅក្នុងខ្សែច្រវាក់ផលិតកម្មស្បៀង ការពង្រីកការធ្វើពាណិជ្ជកម្ម និងការកែលំអហេដ្ឋារចនាសម្ព័ន្ធទីផ្សារក្នុងប្រទេស ២).ត្រូវរៀបចំអាហារទឱ្យកាន់តែងាយស្រួលអាចរកបាន តាមរយៈការពង្រីកកម្មវិធីជំនួយសង្គមដល់បុគ្គលនិងគ្រួសារងាយរងគ្រោះ ដូចជា ការឧបត្ថម្ភសាច់ប្រាក់ កម្មវិធីអាហារតាមសាលារៀនដោយប្រើកសិផលសហគមន៍ និងការប្រើប្រាស់អាហារដោយមានបញ្ចូលមីក្រូសារជាតិទៅក្នុងកម្មវិធីឧបត្ថម្ភមិនមែនសាច់ប្រាក់ជូនប្រជាពលរដ្ឋ ៣).ពង្រីកការផ្តល់ប្រឹក្សាផ្នែកសុខភាពនិងសេវានានាសម្រាប់ម្តាយនិងកុមារអាយុក្រោមពីរឆ្នាំ ក្នុងឱកាសមាស១000 ថ្ងៃដំបូងនៃជីវិត ដោយផ្តោតលើការជំរុញការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ព្រមទាំងការធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់អាហារដល់ទារកនិងកុមារតូច ការបង្កើតរបបអាហារចម្រុះសម្រាប់ម្តាយជាដើម ៤).ជំរុញការអនុវត្តផែនទីបង្ហាញផ្លូវផែនការសកម្មភាពសកលដើម្បីឆ្លើយតបចំពោះបញ្ហាស្គមស្គាំងរបស់កុមារ ៥).ធានាឱ្យមានការទទួលបានទឹកស្អាត អនាម័យនិងទម្លាប់អនាម័យល្អ ៦).កសាងនូវបរិស្ថានស្បៀង ដែលអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តជ្រើសរើសយកអាហារដែលល្អសម្រាប់សុខភាព តាមរយៈការគ្រប់គ្រងលើការផ្សព្វផ្សាយពាណិជ្ជកម្មម្ហូបអាហារ (ដូចជាផលិតផលម្សៅទឹកដោះគោជំនួសទឹកដោះម្តាយ) និងការលើកកម្ពស់ស្តង់ដានិងគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីរបបអាហារ។

ខ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ២០២៥៖** យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨ នឹងឆ្លុះបញ្ចាំងពីក្របខ័ណ្ឌប្រព័ន្ធស្បៀង ហើយកត្តាសំខាន់ៗ ដែលនាំមកនូវការផ្លាស់ប្តូរ នឹងត្រូវបានអនុវត្តដើម្បីសម្រេចទស្សនៈវិស័យឆ្នាំ២០៣០ស្តីពីប្រព័ន្ធស្បៀងប្រកបដោយចីរភាពនិងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។ កម្មវិធីជំនួយសង្គមសម្រាប់គ្រួសារងាយរងគ្រោះនឹងត្រូវពង្រីកការអនុវត្តដោយមានបញ្ចូលសារអប់រំអំពីសារៈសំខាន់នៃអាហារូបត្ថម្ភ ហើយគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីរបបអាហារសម្រាប់មនុស្សពេញវ័យនឹងត្រូវរៀបចំឡើង។ ផែនទីបង្ហាញផ្លូវស្តីពីផែនការសកម្មភាពសកលដើម្បីឆ្លើយតបចំពោះបញ្ហាស្គមស្គាំងរបស់កុមារនឹងត្រូវបានអនុវត្តន៍។ផ្សារគំរូនានានឹងត្រូវបានសាងសង់ឡើងដើម្បីដាក់បង្ហាញឱ្យឃើញពីអាហារសុវត្ថិភាពនិងលើកកម្ពស់ភាពចម្រុះនៃអាហារនិងរបបអាហារសុខភាពដែលមានការគាំទ្រពីវិស័យឯកជន និងសហគមន៍។ ប្រព័ន្ធព័ត៌មាននឹងត្រូវបានដាក់ឱ្យអនុវត្តដើម្បីវាយតម្លៃលើភាគរយគ្រួសារដែលមានលទ្ធភាពទទួលបានរបបអាហារសុខភាព។ សមាគមការពារអ្នកប្រើប្រាស់ថ្នាក់ជាតិមួយនឹងត្រូវបានបង្កើតឡើង ហើយសហគ្រាសឯកជននឹងត្រូវផ្តល់ព័ត៌មានស្តីពីអាហារូបត្ថម្ភនៅលើផលិតផលនានាដែលបានផលិតនិងដាក់លក់។

គ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ ២០៣០៖** របបអាហារសុខភាពនឹងមានភាពងាយស្រួលអាចរកបាន និងមានតម្លៃសមរម្យសម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប។

## ២. លើកកម្ពស់ភាពអត់អាចរបស់យុវជន ស្ត្រី និងជនងាយរងគ្រោះ

**កម្ពុជានឹងបន្តអនុវត្តសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ បង្កើតការងារសមរម្យ អភិវឌ្ឍន៍សហគ្រិននិងបង្កើតឱកាសការងារសម្រាប់យុវជន ស្ត្រីនិងជនងាយរងគ្រោះនៅក្នុងប្រព័ន្ធស្បៀង។** កម្ពុជានឹងបន្តជំរុញឱ្យមានការចូលរួមពីយុវជន ស្ត្រី និងជនងាយរងគ្រោះ ដើម្បីបង្កើនការយល់ដឹងរបស់ពួកគាត់អំពីប្រព័ន្ធស្បៀងនិងអំពីសារៈសំខាន់នៃរបបអាហារសុខភាព បំពាក់បំប៉នពួកគាត់ឱ្យក្លាយជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្តូរក្នុងប្រព័ន្ធស្បៀង។ អ្នកប្រើប្រាស់ ស្ត្រី និងយុវជន គឺជាអ្នកកំណត់ពីប្រព័ន្ធស្បៀងនៅថ្ងៃនេះ និងនៅថ្ងៃអនាគត ហើយមតិយោបល់របស់ពួកគាត់គឺមានសារៈសំខាន់ក្នុងកិច្ចសន្ទនាគោលនយោបាយនិងការធ្វើសម្រេចចិត្ត ដើម្បីឈានទៅសម្រេចចក្ខុវិស័យឆ្នាំ២០៣០។ ការបង្កើតការងារសមរម្យ និងការបង្កើនពលកម្មជំនាញនិងផលិតភាពការងារនៅក្នុងប្រព័ន្ធស្បៀងនៅតាមមូលដ្ឋាន គឺបានរួមចំណែកដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងការនាំចេញ។ ក្នុងបរិបទនៃការស្តារឡើងវិញពីវិបត្តិកូវីដ-១៩ ការគិតគូរពីសុខមាលភាពបុគ្គលនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ គឺមានសារសំខាន់ ដើម្បីផ្តល់ឱកាសឱ្យកុមារទាំងអស់បានចូលរៀន និងសម្រេចបាននូវសក្តានុពលរបស់ពួកគេក្នុងការចូលរួមអភិវឌ្ឍន៍សង្គម។ កម្ពុជានឹងបន្តរៀបចំកិច្ចសន្ទនាដោយមានការចូលរួមពីជនងាយរងគ្រោះ ដើម្បីស្វែងយល់ពីតម្រូវការនិងគោលបំណងរបស់ពួកគាត់ ធ្វើការជាមួយពួកគាត់ដើម្បីកែលម្អប្រព័ន្ធស្បៀងសម្រាប់ផលប្រយោជន៍រួមរបស់ប្រជាជនកម្ពុជាទាំងអស់។

- ក. **កត្តាដែលនាំមកនូវការផ្លាស់ប្តូរប្រព័ន្ធស្បៀង៖** ១).ជំរុញការចូលរួមរបស់យុវជន ជាពិសេសស្ត្រីឱ្យកាន់តួនាទីជាអ្នកដឹកនាំ និងផ្តល់ឱកាសដល់យុវជន ស្ត្រី និងជនងាយរងគ្រោះ ដើម្បីឱ្យពួកគាត់បានចូលរួមជាប្រចាំក្នុងកិច្ចសន្ទនាគោលនយោបាយនិងការធ្វើសេចក្តីសម្រេច ២).ជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថល ការស្រាវជ្រាវនិងការអភិវឌ្ឍ នវានុវត្តន៍ និងគាំទ្រដល់ជនងាយរងគ្រោះ យុវជននិងស្ត្រីដែលជាម្ចាស់សហគ្រាសខ្នាតតូចនិងមធ្យម និង ៣).ពង្រឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងសមាគមយុវជននិងសមាគមស្ត្រី ដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធស្បៀងដែលកំពុងមានការផ្លាស់ប្តូរ និងការអភិវឌ្ឍប្រទេសជាតិ។
- ខ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ២០២៥៖** ការកសាងសមត្ថភាព និងការគាំទ្រនឹងត្រូវបានផ្តល់ដល់យុវជន ស្ត្រីនិងជនងាយរងគ្រោះ ដើម្បីឱ្យពួកគាត់មានលទ្ធភាពចូលរួមនៅក្នុងប្រព័ន្ធស្បៀង និងការលើកកម្ពស់របបអាហារសុខភាពទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងសហគមន៍។ ដើម្បីឆ្លើយតបទៅនឹងឱកាសការងារនៅក្នុងប្រព័ន្ធស្បៀងនៅពេលខាងមុខ ការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈនឹងត្រូវកែសម្រួលដើម្បីឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម និងជំរុញឱ្យមានការចូលរួមពីវិស័យឯកជននិងបង្កើតមជ្ឈមណ្ឌលនវានុវត្តន៍និងសហគ្រាសខ្នាតតូចនិងមធ្យមឱ្យបានកាន់តែច្រើន និងភ្ជាប់ទំនាក់ទំនងសហគ្រាសទាំងនោះជាមួយនឹងវិនិយោគិន។ កម្ពុជានឹងបន្តប្រមូលទិន្នន័យប្រជាជនដោយធ្វើការបែងចែកតាមអាយុនិងភេទជាទៀងទាត់ និងធ្វើបច្ចុប្បន្នភាពផែនការនានា ដើម្បីចូលរួមចំណែកធ្វើឲ្យសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។

គ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ២០៣០៖** យុវជន ស្ត្រីនិងជនងាយរងគ្រោះនឹងត្រូវបានផ្តល់ឱកាសឱ្យបានចូលរួមជាប្រចាំនៅក្នុងកិច្ចសន្ទនាគោលនយោបាយនិងការធ្វើសេចក្តីសម្រេច ហើយការបណ្តុះបណ្តាលវិជ្ជាជីវៈនិងការអប់រំ ការផ្តល់ឱកាសការងារសមរម្យនិងសហគ្រិនភាពក្នុងប្រព័ន្ធស្បៀង នឹងត្រូវបានពង្រីកនិងពង្រឹងបន្ថែម ។

## ៣. ពង្រឹងភាពធន់លើមុខរបរចិញ្ចឹមជីវិតនិងប្រព័ន្ធស្បៀង

**កម្ពុជានឹងបន្តធ្វើសកម្មភាពដោយផ្អែកលើបទពិសោធន៍និងភាពជោគជ័យកន្លងមក ដើម្បីឆ្លើយតបចំពោះភាពងាយរងគ្រោះរ៉ាំរ៉ៃនិងភាពក្រីក្រ និងដើម្បីពង្រឹងភាពធន់របស់តួអង្គពាក់ព័ន្ធក្នុងប្រព័ន្ធស្បៀង ពង្រឹងបណ្តាញនិងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីឆ្លើយតបទៅនឹងវិបត្តិនានា និងបញ្ហាដែលបង្កឡើងដោយមនុស្សនិងអាកាសធាតុ។ កម្ពុជាក៏នឹងបង្កើនសក្តានុពលនៃប្រព័ន្ធស្បៀង ក្នុងការបន្សាំនិងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។** ក្នុងបរិបទនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ការពង្រឹងប្រព័ន្ធសុខាភិបាល សេដ្ឋកិច្ច កសិកម្ម បរិស្ថាន និងប្រព័ន្ធគាំពារសង្គម ដើម្បីពង្រឹងភាពធន់នឹងវិបត្តិនិងដោះស្រាយបញ្ហានានាដែលអាចកើតឡើងនៅពេលអនាគត និងផ្តល់ឱកាសពិសេសសម្រាប់កែលម្អរចនាសម្ព័ន្ធនានាដើម្បីគាំទ្រដល់មុខរបរចិញ្ចឹមជីវិតនិងប្រព័ន្ធស្បៀង។

ដើម្បីលើកកម្ពស់មុខរបរចិញ្ចឹមជីវិតដែលមានភាពធន់ ផែនទីបង្ហាញផ្លូវនេះ នឹងគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច យុវជន ស្ត្រី កសិករខ្នាតតូច និងសហគ្រាសខ្នាតតូចនិងមធ្យមក្នុងវិស័យផលិតកម្មនិងការកែច្នៃស្បៀងអាហារ ដើម្បីពង្រឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទសម្រាប់បង្កើនភាពធន់។ ការស្តារឡើងវិញឱ្យកាន់តែប្រសើរក្រោយវិបត្តិកូវីដ-១៩ គឺត្រូវធ្វើឡើងស្របតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការកសាងសេដ្ឋកិច្ចបៃតង និងការអនុវត្តគោលនយោបាយសំខាន់ៗ នៅក្នុងរបាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២០នៃការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើការតស៊ូមតិដើម្បីជំរុញឱ្យមានកំណើនបៃតង ធានាឱ្យមានការការពារបរិស្ថាននិងសេវាប្រព័ន្ធបរិស្ថាន។

លើសពីនេះ កម្ពុជានឹងបន្តប្រើប្រាស់ប្រព័ន្ធស្បៀងបម្រុងកម្ពុជា កម្មវិធីជំនួយសង្គម និងពង្រីកកម្មវិធីទាំងនេះដើម្បីឆ្លើយតបទៅនឹងវិបត្តិនានា។ ការស្តារឡើងវិញឱ្យកាន់តែប្រសើរឡើងក្រោយវិបត្តិកូវីដ-១៩ កម្ពុជានឹងអនុវត្តគោលការណ៍សុខភាពតែមួយ (One-Health) នៅក្នុងប្រព័ន្ធស្បៀង។

ក. **កត្តាដែលនាំមកនូវការផ្លាស់ប្តូរប្រព័ន្ធស្បៀង៖** ១).ពង្រីកកម្មវិធីគាំពារសង្គមឆ្លើយតបទៅនឹងវិបត្តិ និងរក្សាស្បៀងបម្រុងដើម្បីជួយពង្រឹងភាពធន់ដល់គ្រួសារងាយរងគ្រោះ ២).អនុវត្តគោលការណ៍សុខភាពតែមួយ (One-Health) ដោយរួមទាំងបង្កើតប្រព័ន្ធតាមដានរកប្រភពដើមស្បៀងនៅតាមខ្សែច្រវាក់តម្លៃ ៣).ដឹកនាំការអភិវឌ្ឍប្រព័ន្ធស្បៀងឆ្ពោះទៅសម្រេចបានការអភិវឌ្ឍបៃតងដោយបង្កបរិយាកាសអំណោយផលដល់វិស័យឯកជន ដូចជា ការប្រើប្រាស់ប្រព័ន្ធឌីជីថល ហិរញ្ញប្បទានបៃតង ការកែតម្រូវប្រព័ន្ធក្សេត្របរិស្ថាន ការធ្វើកសិកម្មវៃឆ្លាតដែលគិតគូរពីបរិស្ថាន បង្កើនប្រសិទ្ធភាពប្រើ

ប្រាស់ធនធាន ការកាត់បន្ថយសំណល់និងការខ្វះខាតអាហារ ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធបៃតង រួមទាំងប្រព័ន្ធធារាសាស្ត្រនិងផ្លូវជនបទ។

ខ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ២០២៥៖** ១).ភាពប្រកួតប្រជែងនៃខ្សែច្រវាក់តម្លៃស្បៀង និងមុខរបរចិញ្ចឹមជីវិតរបស់កសិករខ្នាតតូច នឹងត្រូវបានពង្រឹងតាមរយៈការកែលម្អបរិយាកាសទីផ្សារ ២).ប្រព័ន្ធសុខាភិបាលនិងប្រព័ន្ធគាំពារសង្គមនឹងត្រូវបានពង្រឹងទូទាំងប្រទេស ហើយប្រព័ន្ធព័ត៌មាននឹងត្រូវបានបញ្ចូលគ្នាដើម្បីធ្វើឱ្យបានប្រសើរឡើងលើការកំណត់គោលដៅ បង្កើនភាពឆ្លើយតបទៅនឹងវិបត្តិនានា កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការលើកកម្ពស់ការយល់ដឹងនិងធ្វើការប្រាស្រ័យទាក់ទង ៣).ស្បៀងបម្រុងនឹងត្រូវបានរក្សាទុកទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ដើម្បីត្រៀមសម្រាប់ឆ្លើយតបនឹងគ្រោះមហន្តរាយដែលអាចកើតមានក្នុងពេលអនាគត ៤).ហេដ្ឋារចនាសម្ព័ន្ធនានា រួមមានប្រព័ន្ធធារាសាស្ត្រ រោងចក្រកែច្នៃ និងការសម្រួលពាណិជ្ជកម្មនឹងត្រូវបានពង្រឹងក្នុងប្រព័ន្ធស្បៀងទាំងមូល ៥).ហេដ្ឋារចនាសម្ព័ន្ធបៃតងត្រូវទទួលបានគាំទ្រថវិកា ហិរញ្ញប្បទានបៃតងត្រូវបានពង្រីកវិសាលភាព ហើយគោលនយោបាយនានា ដែលមានស្រាប់ នៅក្នុងរបាយការណ៍បច្ចុប្បន្នភាពឆ្នាំ២០២០នៃការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុទាក់ទងទៅនឹងប្រព័ន្ធស្បៀង នឹងត្រូវបានអនុវត្ត។

គ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ២០៣០៖** ភាពធន់របស់គ្រួសារនិងប្រព័ន្ធស្បៀងដើម្បីឆ្លើយតបចំពោះវិបត្តិនានានិងបញ្ហាដែលបង្កឡើងដោយមនុស្សនិងអាកាសធាតុនាពេលអនាគត នឹងត្រូវបានពង្រឹងតាមរយៈការលើកកម្ពស់មុខរបរចិញ្ចឹមជីវិត ការពង្រឹងខ្សែច្រវាក់តម្លៃស្បៀងនិងទីផ្សារ ការពង្រឹងប្រព័ន្ធសុខាភិបាល ការពង្រឹងប្រព័ន្ធគាំពារសង្គម និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុនឹងត្រូវបានពង្រីក ហើយការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនឹងប្រព័ន្ធស្បៀង ចាប់ពីដំណាក់កាលផលិតកម្មរហូតដល់ដំណាក់កាលប្រើប្រាស់ នឹងត្រូវបានពង្រឹងនិងពង្រីកការអនុវត្តន៍។

## ៤. ពង្រឹងអភិបាលកិច្ចដើម្បីធ្វើឱ្យប្រព័ន្ធស្បៀងកាន់តែមានបរិយាប័ន្ន

**ផ្អែកតាមសមិទ្ធផលដែលទទួលបានជោគជ័យពីការរៀបចំកិច្ចសន្ទនាថ្នាក់ជាតិស្តីពីប្រព័ន្ធស្បៀងកម្ពុជានឹងបន្តរៀបចំកិច្ចសន្ទនា ការសម្របសម្រួល និងការសហការជាមួយគ្រប់តួអង្គពាក់ព័ន្ធមកពីវិស័យនានា ដើម្បីឱ្យដំណើរការធ្វើផែនការនិងការអនុវត្តកាន់តែមានបរិយាប័ន្ននិងមានការចូលរួម។** ដំណើរការរៀបចំផែនការនិងការអនុវត្តនឹងត្រូវកែលម្អទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងសហគមន៍ ដោយរួមបញ្ចូលកិច្ចសហការរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងគ្រឹះស្ថានសិក្សានានា។ កិច្ចសន្ទនាទាំងនេះ ផ្តល់ឱកាសដ៏សំខាន់ដើម្បីឱ្យមានការប្រាស្រ័យទាក់ទង និងរំលេចឱ្យឃើញពីអភិក្រមជាច្រើន សម្រាប់ការស្តារឡើងវិញឱ្យកាន់តែប្រសើរ

ក្រោយវិបត្តិកូវីដ-១៩ និងគ្រោះធម្មជាតិនានា ដូចជា ការប្រើប្រាស់អភិក្រមដឹកនាំតាមសហគមន៍ ភាពជាដៃគូរវាងរដ្ឋ ឯកជននិងអ្នកផលិត ការផ្តោតលើអ្នកប្រើប្រាស់និងការផ្សារភ្ជាប់ការងារមនុស្សធម៌ជាមួយការងារអភិវឌ្ឍន៍ និងការងារស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩។ ការផ្សារភ្ជាប់ក្របខ័ណ្ឌច្បាប់ដ៏រឹងមាំសម្រាប់បន្សីគ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺត្រូវការជាចាំបាច់ ហើយគោលនយោបាយ យុទ្ធសាស្ត្រនិងក្របខ័ណ្ឌអភិបាលកិច្ច ត្រូវបានទទួលការគាំទ្រ មានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តដោយមានការបែងចែកការទទួលខុសត្រូវច្បាស់លាស់។

- ក. **កត្តាដែលនាំមកនូវការផ្លាស់ប្តូរប្រព័ន្ធស្បៀង៖** ១).បញ្ចូលប្រធានបទប្រព័ន្ធស្បៀងក្នុងកិច្ចពិភាក្សារបស់ក្រុមការងារបច្ចេកទេសចម្រុះនានា ២).រៀបចំបង្កើតនិងពង្រឹងក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរាជធានី ខេត្ត ៣).គាំទ្រដល់កម្មវិធីអាហារូបត្ថម្ភដឹកនាំដោយសហគមន៍ ៤).បង្កើតនិងពង្រឹងក្រុមយុវជនជើងឯកអាហារូបត្ថម្ភនិងសមាគមស្ត្រី ៥).រៀបចំឱ្យមានការសម្របសម្រួល និងការសហការកាន់តែជិតស្និទ្ធរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជននិងសហគមន៍កសិកម្ម ៦).អនុម័តនិងជំរុញការអនុវត្តច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ និងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ ពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងស្តង់ដាដែលមានស្រាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសុវត្ថិភាពនិងគុណភាពស្បៀង និងរៀបចំមន្ទីរពិសោធន៍ដែល មានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ៧).ជំរុញឱ្យមានការចូលរួមពីបណ្តាញធុរកិច្ចដើម្បីលើកកម្ពស់អាហារូបត្ថម្ភ ៨).គាំទ្រដល់កម្មវិធីសិក្សាស្រាវជ្រាវអំពីបច្ចេកវិទ្យាទំនើបដែលអាចយកមកប្រើប្រាស់នៅក្នុងប្រព័ន្ធស្បៀងនិងគាំទ្រដល់ការស្រាវជ្រាវដើម្បីឱ្យមានការធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមភស្តុតាង ៩).លើកទឹកចិត្តឱ្យមានចីរភាពហិរញ្ញវត្ថុសម្រាប់លើកកម្ពស់ប្រព័ន្ធស្បៀង តាមរយៈការកៀរគរធនធានក្នុងនិងក្រៅប្រទេស។
- ខ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ២០២៥៖** ១).ក្រុមការងារបច្ចេកទេសចម្រុះដែលពាក់ព័ន្ធ នឹងត្រូវបានពង្រឹង ២).វឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ នឹងត្រូវបានចូលរួមពីយុវជន ស្ត្រីនិងជនងាយរងគ្រោះ ៣).ប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងឧបករណ៍តាមដានត្រួតពិនិត្យនឹងត្រូវបានកែលម្អ រួមមានការកត់ត្រាពីការវិនិយោគលើអាហារូបត្ថម្ភ ៤).ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនឹងត្រូវបានពង្រឹង ដូចជាកាត់បន្ថយការលក់ចំណីអាហារដែលប៉ះពាល់សុខភាពនៅតាមសាលារៀន ការរឹតត្បិតលើការផ្សព្វផ្សាយពាណិជ្ជកម្មអាហារដែលប៉ះពាល់សុខភាព និងហាមឃាត់មិនឱ្យមានការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលម៉្សៅទឹកដោះគោជំនួសទឹកដោះម្តាយ។ល។ ៥).ការកសាងសមត្ថភាពរបស់តួអង្គពាក់ព័ន្ធនៅគ្រប់កម្រិតនឹងត្រូវបានលើកកម្ពស់និងពង្រឹង ដើម្បីបញ្ចូលការធ្វើផែនការនិងការវិនិយោគអាហារូបត្ថម្ភដោយក្រុមប្រឹក្សាឃុំ សង្កាត់ ៦).ការសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនឹងត្រូវបានទទួលការគាំទ្រ និងបង្កើនការយកចិត្តទុកដាក់លើប្រព័ន្ធស្បៀង ៧).បណ្តាញទំនាក់ទំនងការងារទាំងនៅថ្នាក់ជាតិ

ថ្នាក់តំបន់និងសកលនឹងត្រូវបានពង្រឹង រួមមាន បណ្តាញចលនាបង្កើនអាហារូបត្ថម្ភ (SUN Movement) អាហារូបត្ថម្ភដើម្បីកំណើន ( Nutrition for Growth) និងគំនិតផ្តួចផ្តើមដទៃទៀត ។

គ. **ផែនការដែលត្រូវសម្រេចនៅឆ្នាំ២០៣០៖** លិខិតបទដ្ឋានគតិយុត្តនានាត្រូវបានបង្កើតឡើង ហើយការអនុវត្តផែនទីបង្ហាញផ្លូវនេះនិងផែនការសកម្មភាពពាក់ព័ន្ធនានា នឹងមានលក្ខណៈបរិយាប័ន្ន និងឆ្លើយតបចំពោះតម្រូវការរបស់អ្នកប្រើប្រាស់និងជនងាយរងគ្រោះ ហើយនឹងលើកទឹកចិត្តដល់ការវិនិយោគប្រកបដោយចីរភាពរបស់វិស័យឯកជននៅក្នុងប្រព័ន្ធស្បៀង។

## ខ.កត្តាផ្លាស់ប្តូរនៅក្នុងពេលពីរនៅបីឆ្នាំខាងមុខ ដើម្បីពន្លឿនវឌ្ឍនភាព

ប្រធានបទដែលនៅសេសសល់មួយចំនួន តម្រូវឱ្យមានការពិភាក្សាបន្ថែមទាំងមុននិងក្រោយពេលកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀង ដោយសារកិច្ចសន្ទនាជាតិបានរៀបចំតាមប្រព័ន្ធអនឡាញដោយគោរពតាមវិធានការរបស់ក្រសួងសុខាភិបាលស្តីពីការទប់ស្កាត់និងបង្ការជំងឺកូវីដ-១៩ ដូច្នេះនៅមានមតិយោបល់សំខាន់ៗមួយចំនួនទៀតមិនបានដាក់បញ្ចូលឱ្យបានគ្រប់គ្រាន់ទេ។ ក្រោយពីកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀង នឹងមានការបន្តរៀបចំកិច្ចសន្ទនាពីថ្នាក់ជាតិទៅសហគមន៍ ជាពិសេសជាមួយនឹងកសិករ អ្នកនេសាទ សហគមន៍ការពារព្រៃឈើ ជនជាតិដើមភាគតិច ស្ត្រីនិងយុវជន ដើម្បីជួយរៀបចំប្រព័ន្ធស្បៀងឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់និងជនងាយរងគ្រោះ។

ផែនទីបង្ហាញផ្លូវនេះ ត្រូវបានរៀបចំឡើង នៅពេលដែលការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដែលបង្ហាញឱ្យឃើញពីវិស័យសំខាន់ៗ ដែលទាមទារឱ្យមានការពន្លឿនសកម្មភាព។ សកម្មភាពអាទិភាពទាំងនេះ នឹងយកមកពិនិត្យនៅដំណាក់កាលស្តារឡើងវិញក្រោយវិបត្តិកូវីដ-១៩ ដើម្បីឆ្លើយតបឱ្យស្របតាមស្ថានការណ៍វិវឌ្ឍន៍នាពេលអនាគតនិងកម្រិតធនធានដែលមាន។ ការឆ្លើយតបទៅនឹងភាពងាយរងគ្រោះនានា ក្នុងដំណាក់កាលស្តារឡើងវិញតម្រូវឱ្យមានការផ្សារភ្ជាប់រវាងការងារមនុស្សធម៌ជាមួយនឹងការងារអភិវឌ្ឍន៍ដើម្បីកសាងឱ្យកាន់តែប្រសើរ។

ការវិនិយោគរបស់វិស័យឯកជនគឺជាកត្តាគន្លឹះក្នុងការផ្លាស់ប្តូរប្រព័ន្ធស្បៀង។ កត្តាដែលនាំមកនូវការផ្លាស់ប្តូរសកម្មភាពក្នុងប្រព័ន្ធស្បៀងនៅកម្ពុជា គឺផ្អែកលើនវានុវត្តន៍ តម្លៃបន្ថែមក្នុងផលិតកម្មកសិកម្ម ការកែលម្អប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងការលើកកម្ពស់គុណភាពនិងសុវត្ថិភាពស្បៀង ។ល។ ក្នុងរយៈពេលពីរបីឆ្នាំទៅមុខទៀត គឺជាឱកាសសម្រាប់ទទួលយកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងឧបករណ៍បញ្ជាពីចំងាយ ដើម្បីគាំទ្រការលើកកម្ពស់ប្រព័ន្ធស្បៀង ដូចជាឧបករណ៍បណ្តុះបណ្តាលនិងផ្សព្វផ្សាយពីចំងាយ ប្រព័ន្ធប្រកាសអាសន្នជាមុន វេទិកាទំនាក់ទំនងនានា ការធ្វើអធិការកិច្ចនិងការត្រួតពិនិត្យពីចំងាយ និងការកត់ត្រាតាមដានតាមប្រព័ន្ធឌីជីថលជាដើម។ ការវិនិយោគរបស់រាជរដ្ឋាភិបាលក្នុងប្រព័ន្ធគាំពារសង្គម កម្មវិធីផ្តល់អាហារតាមសាលារៀន និងកម្មវិធីអាហារូបត្ថម្ភ ព្រមទាំងការអនុវត្តផែនទីបង្ហាញផ្លូវស្តីពីផែនការសកម្មភាពសកលដើម្បីឆ្លើយតបចំពោះបញ្ហាស្គមស្គាំងរបស់កុមារ

នឹងត្រូវបានរៀបចំអនុវត្តដើម្បីឱ្យទទួលផលភ្លាមៗ។ ការកែលម្អប្រព័ន្ធទិន្នន័យ និងបង្កើតភស្តុតាងសម្រាប់ការរៀបចំគោលនយោបាយនិងការធ្វើសេចក្ដីសម្រេចចិត្ត គឺមានសារៈសំខាន់សម្រាប់បណ្ដាឆ្នាំទៅមុខទៀត។

ក្នុងរយៈពេលបីឆ្នាំទៅមុខទៀត គឺជាឱកាសដ៏ពិសេសសម្រាប់កែលម្អរចនាសម្ព័ន្ធ ដើម្បីពន្លឿនការអនុវត្តសកម្មភាពជាអាទិភាពនានា និងកៀរគរធនធានពីប្រភពផ្សេងៗ។ យុទ្ធសាស្រ្តតាមវិស័យនានា នឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០២៣ ដែលផ្ដល់ឱកាសឱ្យយើងអាចបន្សីុក្របខ័ណ្ឌប្រព័ន្ធស្បៀងទៅក្នុងយុទ្ធសាស្រ្តថ្មីៗ របស់ក្រសួងស្ថាប័នពាក់ព័ន្ធដោយផ្ដោតលើអភិក្រមប្រព័ន្ធស្បៀងដ៏ទូលំទូលាយ។ ប្រទេសកម្ពុជាបានចូលរួមជាសមាជិកក្នុងសម្ព័ន្ធកម្មវិធីផ្ដល់អាហារតាមសាលារៀនសកល (Global Coalition for School Feeding) ដែលជាជំហានទី១ក្នុងការចូលរួមក្នុងចលនាពិភពលោកដើម្បីលើកកម្ពស់ប្រព័ន្ធស្បៀង។

## ច.សេចក្ដីសន្និដ្ឋាន

ប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពដ៏ល្អ ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យស្ដីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ដោយឈរលើបរិយាកាសគោលនយោបាយដ៏រឹងមាំ។ ដើម្បីសម្រេចទៅបានយើងត្រូវធ្វើការប្រកបដោយបរិយាប័ន្ន និងមានការចូលរួមពីតួអង្គពាក់ព័ន្ធគ្រប់វិស័យទាំងអស់នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងសហគមន៍។ ដៃគូអភិវឌ្ឍន៍ វិស័យឯកជននិងសង្គមស៊ីវិលនានា ត្រៀមខ្លួនរួចជាស្រេច ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តផែនទីបង្ហាញផ្លូវស្ដីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០។ ខណៈពេលដែលកម្ពុជានឹងក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ វិស័យកសិកម្មនិងប្រព័ន្ធស្បៀង គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់លុបបំបាត់គ្រោះអត់ឃ្លាន កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចីរភាព ដោយធានាថានឹងពុំមាននរណាម្នាក់ត្រូវបានទុកចោលនោះឡើយ។